# សន្តិសុខនៃការបើកប្រាក់ សំរាប់អ្នកម៉ៅការបន្ត

Security of payment for sub-contractors (Khmer)

អ្នកម៉ៅការបន្តខ្លះធ្វើការងារអស់រយៈពេលយ៉ាងយូរ ដោយពុំបានគេបើកប្រាក់ឲ្យទាល់តែសោះ។ ប្រសិនបើលោកអ្នកធ្វើការជាអ្នកម៉ៅការបន្តនៅតាមឧស្សាហកម្មសំណង់អាគារ និងការស្ថាបនាក្នុងរដ្ឋ NSW ហើយមិនបានគេបើកប្រាក់ឲ្យលោកអ្នកអស់រយៈពេលយ៉ាងយូរ លោកអ្នកអាចស្វែងរកជំនួយបាន។

ច្បាប់សន្តិសុខនៃការបើកប្រាក់ឧស្សាហកម្មសំណង់អាគារ និងការស្ថាបនា (Building and Construction Industry Security of Payment Act) ព្យាយាមដោះស្រាយជម្លោះទាំងឡាយលើការបើកប្រាក់។

## តើច្បាប់អនុវត្តដោយបែបណា?

១) ប្រសិនបើអ្នកម៉ៅការបន្តណាម្នាក់ ជឿជាក់ថាខ្លួនមិនបានគេបើកប្រាក់ឲ្យចំពោះការងារដែលខ្លួនបានបំពេញ គេអាចដាក់ពាក្យសុំឲ្យមានការវិនិច្ឆ័យនៅក្រោម Building and Construction Industry Security of Payment Act។ លោកអ្នកអាចដាក់ពាក្យសុំទាមទារជាមួយអ្នកវិនិច្ឆ័យណាម្នាក់។ អ្នកវិនិច្ឆ័យគឺជាជនដែលទទួលខុសត្រូវចំពោះការធ្វើសេចក្តីសំរេចថាតើនរណាជាអ្នកទទួលប្រាក់បើក ហើយថាតើគេនឹងទទួលប្រាក់បើកចំនួនប៉ុន្មាន។

ក) អ្នកម៉ៅការបន្ត ត្រូវបានហៅថា 'អ្នកទាមទារ'

ខ) អ្នកម៉ៅការ ដែលត្រូវបានគេចោទប្រកាន់ថាមិនបានបើកប្រាក់ឲ្យគេត្រូវបានហៅថា 'អ្នកចុងបណ្តឹងឧទ្ធរណ៍'

២) បន្ទាប់មក លោកអ្នកបំពេញពាក្យសុំមួយហៅថា ***សំណើដកយកប្រាក់ (payment withholding request)*** រួចផ្ញើពាក្យសុំនោះទៅឲ្យ***អ្នកម៉ៅការចម្បង***។ នេះគឺជាភាគីដែលទទួលខុសត្រូវចំពោះការបើកប្រាក់ឲ្យ***អ្នកចុងបណ្តឹងឧទ្ធរណ៍***។

៣) អ្នកម៉ៅការចម្បង មិនបានអនុញ្ញាតបើកប្រាក់ទៅឲ្យអ្នកចុងបណ្តឹងឧទ្ធរណ៍ឡើយ លុះត្រាតែបន្ទាប់ពីដំណើរការវិនិច្ឆ័យបានធ្វើចប់សព្វគ្រប់។

៤) បន្ទាប់មកអ្នកវិនិច្ឆ័យសំរេច ថាតើលោកអ្នកគួរទទួលប្រាក់បើកឬទេ។

## ព័ត៌មានសំខាន់

- Security of Payment Act ត្រូវបានគេយកអនុវត្តដើម្បីវិនិច្ឆ័យលើជម្លោះពាណិជ្ជកម្ម។ លោកអ្នកអាចប្តឹងជំទាស់នឹងអ្នកម៉ៅការឯទៀត ឬទាំងអ្នកម៉ៅការចម្បង ក៏ប៉ុន្តែលោកអ្នកមិនអាចអនុវត្តច្បាប់នេះដើម្បីទាមទារប្រាក់បើកពីម្ចាស់ផ្ទះឯកជនឡើយ។
- ប្រសិនបើលោកអ្នកមិនបានគេបើកប្រាក់ឲ្យ ចំពោះការងារដែលលោកអ្នកបានបំពេញចំពោះផ្ទះនរណាម្នាក់ លោកអ្នកគួរតែនិយាយទៅកាន់អ្នកប្រឹក្សាផ្នែកច្បាប់របស់លោកអ្នក សហជីពរបស់លោកអ្នក ឬនរណាម្នាក់មកពីសហគមន៍របស់លោកអ្នក។
- អ្នកម៉ៅការបន្ត អាចបង្ខាំងទុកប្រាក់ដែលស្មើនឹងតម្លៃនៃការទាមទារប៉ុណ្ណោះ។
- 'អ្នកម៉ៅការចម្បង' មិនទទួលខុសត្រូវចំពោះការបើកប្រាក់ឲ្យលោកអ្នកទេ។ អ្នកម៉ៅការចម្បង អាចគ្រាន់តែបញ្ឈប់ប្រាក់ពីការបើកទៅឲ្យអ្នកចុងបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ។

## ព័ត៌មានបន្ថែមទៀត

### ឱវាទផ្នែកច្បាប់ ហិរញ្ញវត្ថុ ឬវិជ្ជាជីវៈ

អ្នកម៉ៅការបន្ត ត្រូវបានទូន្មានឲ្យពិភាក្សាអំពីរឿងនេះជាមួយអ្នកផ្តល់ឱវាទផ្នែកច្បាប់ សហជីព ឬអ្នកគាំទ្ររបស់គេ។

### ពាក្យបំពេញសំណើដកយកប្រាក់ (Payment withholding request)

បន្ថែមទៅនឹងពាក្យបំពេញសំរាប់ការវិនិច្ឆ័យ អ្នកម៉ៅការបន្តត្រូវការដាក់ពាក្យសុំ សំណើដកយកប្រាក់ រួចចុះហត្ថលេខាលើសេចក្តីប្រកាសផ្លូវការមួយច្បាប់។

### ការវិនិច្ឆ័យឯករាជ្យ

ការទទួលខុសត្រូវចំពោះដំណើរការកំណត់លើការបើកប្រាក់នៅក្រោម Security of Payment Act គឺផ្អែកទៅលើអ្នកវិនិច្ឆ័យឯករាជ្យ ជាអាជ្ញាជ្រើសតាំងដែលបានទទួលការអនុញ្ញាតស្របច្បាប់ ហើយត្រូវបានតែងតាំងឡើង (Authorised Nominating Authorities) ។

ចំពោះព័ត៌មានច្រើនថែមទៀត សូមបើកមើលវិបសាយ www.services.nsw.gov.au/securityofpayment ឬទូរស័ព្ទលេខ 1800 679 289។

ចំពោះជំនួយផ្នែកភាសា សូមទូរស័ព្ទសេវាបកប្រែភាសាអត្ថបទ និងនិយាយ (TIS) លេខ 13 14 50 រួចស្នើសុំអ្នកបកប្រែភាសាជាភាសារបស់លោកអ្នក។

**ការបដិសេធ:** លោកអ្នកមិនត្រូវផ្អែកទៅលើការបោះពុម្ពផ្សាយនេះថាជាឱវាទផ្នែកច្បាប់ឡើយ។ ចំពោះព័ត៌មានច្រើនថែមទៀត សូមយោងទៅច្បាប់ដែលពាក់ព័ន្ធ។



© State of New South Wales 2011